## មតិរបស់សមាជិកសហគមន៍



**កសិករដាំបន្លែ**
**លោក ស្រី យ៉ូន**

នៅពេលដែល ខ្ញុំជាកសិករ មិនបានចូលរួម ជាមួយ សហគមន៍ តម្លៃផលិតផលរបស់ខ្ញុំគឺមានតម្លៃទាប ដូច្នេះ ខ្ញុំបានសម្រេចចិត្ត ចូលរួមជាមួយ'សហគមន៍កសិកម្ម ដើម្បីបង្កើនប្រាក់ចំណូលរបស់ខ្ញុំ។ ជីវភាពគ្រួសាររបស់ ខ្ញុំ មានភាពប្រសើរឡើងជាងមុន។ ខ្ញុំក៏បានប្រើប្រាស់ សេវាកម្ម ជាឧបករណ៍ស្រោចស្រព ពីសហគមន៍ផង ដែរ។



**កសិករដាំបន្លែ**
**លោក សាន ណុប**

សមាជិកសហគមន៍កសិកម្ម បានមកកន្លែងខ្ញុំជាប្រចាំ និងផ្តល់នូវដំបូន្មានខ្លះៗអំពីថ្នាំសម្លាប់សត្វល្អិត និងជី ជាដើម។ មុនពេលចូលរួមជាមួយ សហគមន៍កសិកម្ម ខ្ញុំមិនបានទទួលចំណេះដឹងអំពីរឿងទាំងនេះទេ ដូច្នេះ វាពិតជាមានប្រយោជន៍សម្រាប់ខ្ញុំ។



**កសិករដាំបន្លែ /**
**សមាជិកក្រុមប្រឹក្សាភិបាល**
**លោកស្រី ព្រំ ភិម**

មុនពេលចូលរួមជាមួយ សហគមន៍កសិកម្ម ពេលខ្លះការ ចំណាយគឺ លើសពីប្រាក់ចំណូល ព្រោះតម្លៃទំនិញ អាស្រ័យលើតម្លៃទីផ្សារ។ សហគមន៍កសិកម្ម ទិញ ផលិតផលរបស់ខ្ញុំ ស្ទើរតែក្នុងតម្លៃថេរជានិច្ច ដូច្នេះនៅ ពេលនេះ ប្រាក់ចំណូលរបស់ខ្ញុំគឺ មានស្ថេរភាព។ ខ្ញុំពិត ជាសប្បាយចិត្ត នៅពេលដែលខ្ញុំបានជាប់ឆ្នោតជា សមាជិកក្រុមប្រឹក្សាភិបាល ក្នុងឆ្នាំ២០០៩។ ខ្ញុំចង់ចូលរួម ចំណែកដើម្បីធ្វើឱ្យសមាជិកមានជីវភាពប្រសើរឡើង។

## អំពីសហគមន៍កសិកម្មបន្លែចម្រុះជាយក្រុងកំពង់ស្ពឺ (PUAC)

ការប្រើប្រាស់សម្ភារដូចជា ឡានដឹកទំនិញ ម៉ាស៊ីនកិន ស្រូវ និងម៉ាស៊ីនសម្ងួត ព្រមទាំងប្រព័ន្ធស្រោចស្រពធ្វើ ឲ្យយើងអាចផ្គត់ផ្គង់សមាជិក បានទូលំទូលាយចាប់ពី ផលិតកម្ម រហូតដល់ទីផ្សារបន្លែ និងអង្ករ។ លើសពី នេះទៅទៀត សហគមន៍កសិកម្ម មានទំនាក់ទំនង យ៉ាងរឹងមាំជាមួយសហគមន៍កសិកម្មផ្សេងៗ អ្នកលក់ ដុំ និងក្រុមហ៊ុនផលិតគ្រាប់ពូជជាដើម។ ដូច្នេះយើង អាចធ្វើអាជីវកម្មបាន កាន់តែមានប្រសិទ្ធភាព។

**<u>ទស្សនៈវិស័យរបស់ប្រធានក្រុមប្រឹក្សាភិបាល</u>**



លោកស្រី យូ លន់

ប្រធានក្រុមប្រឹក្សាភិបាល
PUAC

គោលដៅរបស់យើងគឺ សមាជិកអាច ទទួលបានប្រាក់ ចំណូលសមរម្យ និងមានជីវិតប្រសើរជាងមុន។ ដើម្បី សម្រេចបានយើងផលិតនូវផលិតផលដែលល្អសម្រាប់ សុខភាព និងមានសុវត្ថិភាព ហើយលក់ផលិតផល ទាំងនោះនៅលើទីផ្សារ។ យើងក៏ផ្តោតលើ ការពង្រឹង សមត្ថភាពសមាជិករបស់យើងផងដែរ។

**<u>ព័ត៌មានទូទៅ៖</u>**

បានបង្កើត៖ ខែឧសភា ឆ្នាំ2009

សមាជិកសរុបចំនួន៖ 1,235នាក់ (ស្រី 812នាក់)

ដើមទុន៖ 3,355,902,000 រៀល

ភាគហ៊ុនសរុប៖ 25,786 ហ៊ុន

តម្លៃក្នុង1ហ៊ុន៖ 30,000 រៀល

# សហគមន៍កសិកម្ម បន្លែចម្រុះជាយក្រុង កំពង់ស្ពឺ (PUAC)




ភូមិ ចំការដូង ឃុំច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ប្រទេសកម្ពុជា (ចម្ងាយប្រហែល 50km ពីទីក្រុងភ្នំពេញ)

លេខទូរស័ព្ទទំនាក់ទំនង:
016-540 246
096-546-7398
077-782-565



Technically supported by BPAC Project
(MAFF&JICA)

# ទីផ្សារបន្លែ

## ទីផ្សាររបស់យើង

យើងធ្វើការប្រមូលបន្លែ មិនត្រឹមតែ ពីសហគមន៍កសិកម្មរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីសហគមន៍កសិកម្មដទៃទៀតនៅខេត្តកំពង់ស្ពឺផងដែរ។ សហគមន៍កសិកម្មរបស់យើងសហការ ជាមួយអ្នកលក់ដុំ និងអ្នកចែកចាយជាង ៤០នាក់ ដូចជាផលិតផលកសិកម្មជប៉ុន សួនបៃតង និងខេអេសជី (KSG)។ បន្លែប្រមាណ ១០៩ តោនត្រូវបានដឹកជញ្ជូនជារៀងរាល់ឆ្នាំ ដោយក្រុមហ៊ុនដែលបានបញ្ជាទិញ ហើយសហគមន៍ក៏មានឡានដឹកទំនិញផ្ទាល់ខ្លួនផងដែរ។



ឡានដឹកទំនិញ (Refrigerated truck)



ទីតាំងប្រមូលបន្លែក្នុងសហគមន៍កសិកម្ម

| ការដឹកជញ្ជូនបន្លែ | រដូវប្រាំង (មករា - មេសា) | រដូវវស្សា (ឧសភា - ធ្នូ) |
| --- | --- | --- |
| បន្លែប្រភេទស្លឹក | 16.8 តោន | 19.2 តោន |
| បន្លែប្រភេទផ្លែ | 36.0 តោន | 47.0 តោន |
| **សរុប** | **52.8 តោន** | **66.2 តោន** |

(ឆ្នាំ 2019)

## ប្រភេទបន្លែ

យើងផលិត និងផ្គត់ផ្គង់ បន្លែប្រភេទស្លឹកជាច្រើនប្រភេទ (រួមមាន ស្ពៃ សាឡាត់ ជាដើម) និងបន្លែប្រភេទផ្លែ (ប៉េងប៉ោះ ត្រប់វែង ពោតបារាំង ត្រសក់ ។ល។) ដើម្បីឆ្លើយតបទៅនឹង តម្រូវការទីផ្សារ។ ថ្មីៗនេះយើងក៏កំពុងផ្ដោត ការយកចិត្តទុកដាក់ ទៅលើការផលិត “oba” (ឱសថបុរាណជប៉ុន) សម្រាប់ទីផ្សារ ផ្សារទំនើបរបស់ជប៉ុនផងដែរ។








## ទីផ្សារសម្រាប់ទីរួមខេត្ត

បន្លែរបស់យើង មិនត្រឹមតែសម្រាប់អ្នកលក់ដុំដែលបានចុះកិច្ចសន្យាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដឹកជញ្ជូន ទៅដល់ផ្សារទីរួមខេត្តទៀតផង។ ផលិតផលត្រូវបានដឹកបញ្ជូន ទៅកាន់ទីផ្សារដោយផ្ទាល់ ដោយឡានដឹកទំនិញ (Refrigerated truck) របស់យើង ដូច្នេះអតិថិជនអាចទិញបាននូវបន្លែស្រស់ល្អ។



# ការផ្គត់ផ្គង់គ្រាប់ពូជ

## គ្រាប់ពូជបន្លែ

**ការទិញ**: យើងទិញគ្រាប់ពូជ ដែលមានគុណភាពខ្ពស់ចំនួន ៣៦ ប្រភេទ (សាឡាត់ ត្រសក់ ពោតបារាំង ។ល។ ) ពីក្រុមហ៊ុន “ត្រាងណុង” ដែលជាក្រុមហ៊ុនគ្រាប់ពូជ គូរឲ្យទុកចិត្តមួយនៅប្រទេស វៀតណាម។

**ការរក្សាទុក**: ដើម្បីរក្សាបាននូវគុណភាព គ្រាប់ពូជត្រូវបានរក្សាទុកក្នុងទូរទឹកកកដែលមានសីតុណ្ហភាពត្រឹម ១៣ អង្សាសេ ក្នុងសហគមន៍កសិកម្ម។

**ការលក់**: គ្រាប់ពូជ ត្រូវបានលក់ជូនតែសមាជិកសហគមន៍កសិកម្មតែប៉ុណ្ណោះ។ ពួកគេអាចទិញគ្រាប់ពូជដែលមានគុណភាពខ្ពស់ ក្នុងតម្លៃទាប។






គ្រាប់ពូជបន្លែ ពីក្រុមហ៊ុន “ត្រាងណុង”

## ពូជស្រូវ

**ការទិញ**: ពូជស្រូវដែលពេញនិយម “ផ្ការំដួល” ត្រូវបានទិញពី “សហគមន៍កសិកម្ម ស្វាយចចិបមានជ័យ” ក្នុងខេត្តកំពង់ស្ពឺ។

**ការរក្សាទុក**: គ្រាប់ពូជត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវនៅក្នុងឃ្លាំង។ (ប្រហែល ៣ គីឡូម៉ែត្រពីសហគមន៍កសិកម្ម)។

**ការលក់**: សមាជិកសហគមន៍កសិកម្មទាំងអស់ អាចទិញគ្រាប់ពូជស្រូវបាន ក្នុងតម្លៃទាបជាង អ្នកដែលមិនមែនជាសមាជិក។